# ព្រះរាជក្រម

នស/រកម/១០០៥/០២៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិកសម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិក សម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក

### មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការកំណត់សម្គាល់នៃគ្រឿងផ្ទុះប្លាស្ទិកសម្រាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ដែលធ្វើនៅទីក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

### មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

### មាត្រា ៣.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

៣/រល-០៤១០.៤៥៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់ ញឹក ប៊ុនឆៃ

លេខ: ៣៨៦ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ តុលា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាវី តាន់

# ឧបសម្ព័ន្ធ I

# អនុសញ្ញាស្តីពី ការកំណត់សំគាល់ នៃគ្រឿងផ្ទុះប្លាស្ទិកសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក

## រដ្ឋភាគីនៅនឹងអនុសញ្ញា :

-ដោយដឹងថាមានការជាប់ទាក់ទងអំពើភេរវកម្មចំពោះសន្តិសុខអន្តរជាតិ

-ដោយមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអំពើភេរវកម្ម បានបំផ្លិចបំផ្លាញយន្តហោះ មធ្យោបាយដឹកជញ្ជូននានា និងគោលដៅផ្សេងៗទៀត

-ដោយព្រួយបារម្ភថាគ្រឿងផ្ទុះប្លាស្ទិកត្រូវបានប្រើប្រាស់សំរាប់ភេរវកម្ម

-ដោយពិចារណាឃើញថា ការកំណត់សំគាល់គ្រឿងផ្ទុះប្រភេទប្លាស្ទិកជាកម្មវត្ថុនៃការស្រាវជ្រាវរក អាចជាជំនួយយ៉ាងសំខាន់ដើម្បីទប់ស្កាត់អំពើខុសច្បាប់

-ដោយទទួលស្គាល់ថា វត្ថុបំណងដើម្បីរារាំងអំពើខុសច្បាប់បែបនេះ ជាតម្រូវការចាំបាច់ជាបន្ទាន់សំរាប់បណ្តារដ្ឋ ដែលគោរពតាមលិខិតុបករណ៍អន្តរជាតិដើម្បីអនុម័តវិធានការសមស្របសំដៅធានាថា គ្រឿងផ្ទុះប្លាស្ទិកត្រូវបានកំណត់សំគាល់ដ៏ត្រឹមត្រូវ

-ដោយពិចារណាឃើញថា សេចក្តីសំរេចនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ៦៣៥ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៨៩ និងសេចក្តីសំរេចនៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ ៤៤-២៩ ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ១៩៨៩ ដែលជំរុញអោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីពង្រឹងកិច្ចការរបស់ខ្លួនក្នុងការបង្កើត ប្រព័ន្ធអន្តរជាតិសំរាប់ការកត់សំគាល់គ្រឿងផ្ទុះប្លាស្ទិក ឬបន្ទុះគ្រឿងផ្ទុះដែលជាកម្មវត្ថុនៃការស្រាវជ្រាវរក

-ដោយបានគិតគូរយកចិត្តទុកដាក់ទៅនឹងសេចក្តីសំរេច A ២៧-៨ ដែលបានអនុម័តជាឯកច្ឆ័ន្ទនាសម័យប្រជុំលើកទី ២៧ នៃសន្និបាតអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលបានយល់ព្រមប្រកបដោយអទិភាពខ្ពស់ និងលើសលប់ទៅនឹងការរៀបចំលិខិតុបករណ៍អន្តរជាតិថ្មីមួយសំរាប់កំណត់សំគាល់គ្រឿងផ្ទុះប្លាស្ទិក ឬបន្ទុះគ្រឿងផ្ទុះ ដែលត្រូវស្រាវជ្រាវរក

-ដោយមានការកត់សំគាល់ដោយក្តីសោមនស្ស ដល់តួនាទីរបស់ក្រុមប្រឹក្សាអាកាសចរណ៍ស៊ីវិលអន្តរជាតិ ក្នុងការរៀបចំអនុសញ្ញានេះ ក៏ដូចជាឆន្ទះរបស់ក្រុមប្រឹក្សាអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីទទួលកាន់កាប់មុខងារ ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តន៍របស់ខ្លួន

## បានព្រមព្រៀងដូចខាងក្រោម :

## មាត្រា ១
## គោលបំណងនៃអនុសញ្ញានេះ

១-"គ្រឿងផ្ទុះ" មានន័យថា ផលិតផលជាតិផ្ទុះដែលទូទៅគេស្គាល់ថាជា "គ្រឿងផ្ទុះប្លាស្ទិក" រួមមានប្រភេទគ្រឿងផ្ទុះទាំងឡាយដែលមានទ្រង់ទ្រាយជាបន្ទះយឺត ឬបត់បែនបានដូចមានចែងនៅក្នុងឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។

២-"សារធាតុភ្នាក់ងាររុករក" មានន័យថាសារធាតុមួយដូចមាន ចែងក្នុងឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញា នេះ ដែលត្រូវបាន ដាក់បញ្ចូលទៅក្នុងគ្រឿងផ្ទុះដើម្បីធ្វើអោយសារធាតុមួយនេះអាចស្រូបបាន ។

៣-"ការដាក់សំគាល់" មានន័យថា ការដាក់បញ្ចូលទៅក្នុងគ្រឿងផ្ទុះនូវ សារធាតុភ្នាក់ងាររុករកដោយអនុលោមតាមឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។

៤-"ការផលិត" មានន័យថាជាដំណើរការផលិត ដោយរាប់ទាំងដំណើរការផលិតជាថ្មីនៃការផលិត គ្រឿងផ្ទុះ ។

៥-"ឧបករណ៍ស្របច្បាប់" ត្រូវមាន ប៉ុន្តែមិនកំរិតចំពោះ គ្រាប់កាំភ្លើងធំ គ្រាប់បែកធំៗ គ្រាប់បាញ់រយៈចំងាយឆ្ងាយ គ្រាប់មីន គ្រាប់មីស៊ីល គ្រាប់រ៉ុកកែត វិសេវផ្ទុះ គ្រាប់បែកដៃ ហើយនិងគ្រឿង ទំលុះដែលផលិតឡើងយ៉ាងពិសេសសំរាប់គោលបំណងយោធា និងប៉ូលីសស្របតាមច្បាប់ និងបទបញ្ជារបស់ រដ្ឋភាគីដែលជាប់ពាក់ព័ន្ធ ។

៦-"រដ្ឋផលិត" មានន័យថា រដ្ឋដែលនៅក្នុងទឹកដីរបស់ខ្លួនមានគ្រឿងផ្ទុះត្រូវបានផលិត ។

## មាត្រា ២

រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ និងមានប្រសិទ្ធិភាពដើម្បីហាមឃាត់ និងទប់ស្កាត់ការផលិតនៅក្នុងទឹកដីរបស់ខ្លួននូវគ្រឿងផ្ទុះមិនសំគាល់បាន ។

## មាត្រា ៣

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា និងមានប្រសិទ្ធិភាពដើម្បីហាមឃាត់ និងទប់ស្កាត់ការចល័តទាំងនៅខាងក្នុង ឬនៅខាងក្រៅនៃទឹកដីរបស់ខ្លួននូវគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បាន ។

២-ចំពោះវាក្យខ័ណ្ឌខាងលើនឹងមិនយកមកអនុវត្ត ចំពោះការចល័តក្នុងបំណងមិនស្របទៅនឹងគោលបំណង នៃអនុសញ្ញាដោយអាជ្ញាធរនៃរដ្ឋភាគី ចំពោះមុខងារជាយោធា ឬប៉ូលីសនូវគ្រឿងផ្ទុះទាំងឡាយ ដែលមិនសំគាល់បាន ហើយស្ថិតនៅក្រោមការត្រួតពិនិត្យនៃរដ្ឋជាភាគីនោះ ដូចមានចែងក្នុងវាក្យខ័ណ្ឌ១ នៃមាត្រា៤ ។

## មាត្រា ៤

១-រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីអនុវត្តម៉ឺងម៉ាត់ និងត្រួតពិនិត្យដ៏មានប្រសិទ្ធភាព ទៅលើកម្មសិទ្ធិ និងការផ្ទេរកម្មសិទ្ធិនៃគ្រឿងផ្ទុះមិនសំគាល់បាននេះ ដែលត្រូវបានផលិតនៅក្នុង ឬនាំចូលមកក្នុងទឹកដីរបស់ខ្លួន មុនពេលអនុសញ្ញានេះ ចូលជាធរមានចំពោះរដ្ឋនោះ ដើម្បីទប់ស្កាត់ការប្រើប្រាស់ខុសទិសដៅ ឬមិនស្របតាមគោលបំណងនៃអនុសញ្ញានេះ ។

២.រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាថា រាល់ការស្តុកនៃគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បានដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ហើយដែលមិនកាន់កាប់ដោយអាជ្ញាធររបស់ខ្លួន ដែលមានមុខងារជាយោធា ឬប៉ូលីស នោះត្រូវកំទេចចោល ឬដុតបំផ្លាញចោល ប្រសិនបើការប្រើប្រាស់នោះមិនស្របទៅនឹងគោលបំណង នៃអនុសញ្ញានេះ ដោយបញ្ជាក់ច្បាស់ ឬបានធ្វើអោយអស់ប្រសិទ្ធិភាពជាអចិន្ត្រៃយ៍ក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនោះ ។

៣. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថា ការស្តុកទាំងអស់នៃគ្រឿងផ្ទុះទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១នៃមាត្រានេះ ហើយដែលកាន់កាប់ដោយអាជ្ញាធររបស់ខ្លួន ដែលមានមុខងារជាយោធា ឬប៉ូលីស ហើយដែលមិនបានបញ្ចូលជាផ្នែកតែមួយ នៃយុទ្ធោបករណ៍ស្របច្បាប់ គឺត្រូវកំទេចចោល ឬធ្វើអោយអស់ប្រសិទ្ធិភាព ប្រសិនបើការប្រើប្រាស់នោះមិនស្របទៅនឹងគោលបំណងនៃអនុសញ្ញានេះដោយបង្ហាញ ឬបញ្ជាក់ថាបានធ្វើអោយអស់ប្រសិទ្ធភាពជាអចិន្ត្រៃយ៍ក្នុងរយៈពេល ១៥ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនោះ ។

៤.រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាដល់ការបំផ្លាញអោយបានឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបានក្នុងទឹកដីរបស់ខ្លួន នូវគ្រឿងផ្ទុះទាំងឡាយដែលមិនសំគាល់បាន ហើយដែលអាចត្រូវបានរកឃើញនៅនឹងកន្លែង ហើយដែលមិនមានចែងនៅក្នុងកថាខ័ណ្ឌខាងដើមនៃមាត្រានេះ ក្រៅអំពីស្តុកនៃគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បាន ហើយដែលកាន់កាប់ដោយអាជ្ញាធររបស់ខ្លួន ដែលមានមុខងារជាយោធា ឬប៉ូលីស និងមិនបានបញ្ចូលជាផ្នែកតែមួយនៃយុទ្ធោបករណ៍ស្របច្បាប់នៅថ្ងៃ ដែលអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋនោះ ។

៥.រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់នានាដើម្បីអនុវត្តម៉ឺងម៉ាត់ និងមានប្រសិទ្ធិភាពក្នុងការត្រួតពិនិត្យទៅលើកម្មសិទ្ធិ និងការផ្ទេរកម្មសិទ្ធិនៃគ្រឿងផ្ទុះទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ នៃភាគ ១ នៃឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញានេះ ដើម្បីទប់ស្កាត់ការប្រើប្រាស់ខុសទិសដៅ ឬការប្រើប្រាស់មិនសមស្របទៅនឹងវត្ថុបំណងនៃអនុសញ្ញានេះ ។

៦.រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាដល់ការបំផ្លាញអោយបានឆាប់រហ័សបំផុត តាមការដែលអាចធ្វើទៅបាន នៅក្នុងទឹកដីរបស់ខ្លួននូវគ្រឿងផ្ទុះទាំងឡាយមិនអាចសំគាល់បាន ដែលបានផលិតចាប់តាំងពីអនុសញ្ញានេះបានចូលជាធរមានចំពោះរដ្ឋនោះ ហើយដែលមិនមានចែងជាក់លាក់នៅក្នុងវាក្យខ័ណ្ឌ ២ d នៃភាគ ១ នៃឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញានេះហើយនិងគ្រឿងផ្ទុះទាំងឡាយមិនសំគាល់បានជាច្រើនទៀត ដែលមិនមានចែងនៅក្នុងវាក្យខ័ណ្ឌផ្សេងៗនៃកថាខ័ណ្ឌ II នៃឧបសម្ព័ន្ធបច្ចេកទេស ។

## មាត្រា ៥

១.មានការបង្កើតឡើងដោយអនុសញ្ញានេះ នូវគណៈកម្មការបច្ចេកទេសគ្រឿងផ្ទុះអន្តរជាតិមួយ (ក្រោយមកហៅថា"គណៈកម្មការ") ដែលមានសមាជិកមិនតិចជាង ១៥ នាក់ ហើយក៏មិនលើសពី ១៩ នាក់ ហើយដែលត្រូវបានតែង

តាំងឡើងដោយក្រុមប្រឹក្សានៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ( ក្រោយមកហៅថា ក្រុមប្រឹក្សា ) ដែលសមាជិកទាំងនោះត្រូវបានតែងតាំងពីក្នុងចំណោមបណ្តារដ្ឋភាគីនៃអនុសញ្ញានេះ ។

២-សមាជិកនៃគណៈកម្មការនេះត្រូវតែជាអ្នកជំនាញ ដែលមានបទពិសោធន៍ច្រើន និងដោយផ្ទាល់ក្នុងរាល់កិច្ចការដែលជាប់ទាក់ទងទៅនឹងការផលិត ការសិក្សាស្វែងយល់ និងការស្រាវជ្រាវអំពីគ្រឿងផ្ទុះ ។

៣-សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវបំពេញការងាររយៈពេល ៣ ឆ្នាំ ហើយអាចនឹងត្រូវបានជ្រើសតាំងជាថ្មីបន្តទៀត ។

៤-សម័យប្រជុំនៃគណៈកម្មការនេះត្រូវកោះប្រជុំយ៉ាងតិច ១ ដងក្នុងមួយឆ្នាំ នៅទីស្នាក់ការនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ឬនៅកន្លែងនិងពេលវេលា ដែលកំណត់ ឬសំរេចដោយក្រុមប្រឹក្សា ។

៥- គណៈកម្មការនេះត្រូវអនុម័តនូវច្បាប់នៃនីតិវិធីរបស់ខ្លួន ដោយមានការយល់ព្រមពីក្រុមប្រឹក្សា ។

## មាត្រា ៦

១- គណៈកម្មការត្រូវវាយតំលៃ ការអភិវឌ្ឍន៍ផ្នែកបច្ចេកទេសដែលទាក់ទងទៅនឹងការផលិត ការកំណត់សំគាល់ និងការស្រាវជ្រាវរកគ្រឿងផ្ទុះ ។

២-តាមរយៈក្រុមប្រឹក្សាគណៈកម្មការនេះត្រូវរាយការណ៍ ការរកឃើញរបស់ខ្លួនទៅរដ្ឋភាគី និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ។

៣-គ្រប់ពេលដែលចាំបាច់គណៈកម្មការ ត្រូវធ្វើអនុសាសន៍ផ្ញើជូនទៅក្រុមប្រឹក្សា ដើម្បីធ្វើវិសោធនកម្មលើឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។ គណៈកម្មការត្រូវខិតខំប្រឹងប្រែងដើម្បីធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួន លើអនុសាសន៍ដោយសំឡេងកុងសង់ស៊ីស ។ ក្នុងករណីដែលមិនមានកុងសង់ស៊ីស គណៈកម្មការត្រូវធ្វើសេចក្តីសំរេចដោយការបោះឆ្នោតយកសម្លេងភាគច្រើន ២/៣ នៃសមាជិកទាំងមូល ។

៤-យោងតាមអនុសាសន៍របស់គណៈកម្មការក្រុមប្រឹក្សា អាចដាក់ស្នើទៅរដ្ឋភាគីដើម្បីធ្វើវិសោធនកម្មលើឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះបាន ។

## មាត្រា ៧

១-រដ្ឋភាគីនីមួយៗអាចបញ្ជូនសេចក្តីពន្យល់របស់ខ្លួនទៅក្រុមប្រឹក្សា បានក្នុងរយៈពេល ៩០ថ្ងៃ ចាប់ពីថ្ងៃ ដែលបានប្រកាសជូនដំណឹងអំពីសំណើវិសោធនកម្ម ទៅលើឧបសម្ព័ន្ធបច្ចេកទេស នៃអនុសញ្ញានេះ ។ ក្រុមប្រឹក្សាត្រូវបញ្ជូនសេចក្តីពន្យល់នេះទៅគណៈកម្មការ អោយបានឆាប់រហ័សតាមការដែលអាចធ្វើទៅបាន ដើម្បីគណៈកម្មការធ្វើការពិចារណា។ ក្រុមប្រឹក្សាត្រូវអញ្ជើញរដ្ឋភាគី ដែលបានផ្តល់សេចក្តីពន្យល់ ឬការជំទាស់របស់ខ្លួន លើសំណើវិសោធនកម្ម ដែលបានស្នើឡើងនេះ ដើម្បីពិគ្រោះជាមួយគណៈកម្មការ ។

២-គណៈកម្មការត្រូវពិចារណាយោបល់ របស់រដ្ឋភាគីទាំងឡាយដែលបានស្នើឡើង ដោយអនុលោមតាមកថាខ័ណ្ឌខាងលើ ហើយត្រូវរាយការណ៍ជូនមក ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សា បន្ទាប់ពីធ្វើការពិចារណាលើរបាយការណ៍ របស់គណៈកម្មការ និងធ្វើការវិភាគទៅលើខ្លឹមសារនៃវិសោធនកម្ម និងសេចក្តីពន្យល់របស់រដ្ឋភាគីទាំងអស់គិតទាំងរដ្ឋដែលជាអ្នកស្នើផង មុននឹងដាក់សំណើវិសោធនកម្មជូនរដ្ឋភាគីទាំងអស់ដើម្បីធ្វើការអនុម័ត ។

៣-ប្រសិនបើសំណើវិសោធនកម្ម ដែលដាក់ស្នើនេះមិនមានការជំទាស់ពីរដ្ឋភាគីចំនួនប្រាំ ឬលើសពីនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមក ក្រុមប្រឹក្សា ក្នុងរយៈពេល៩០ថ្ងៃ ចាប់ពីថ្ងៃដែលបានប្រកាសជូនដំណឹងអំពីសំណើវិសោធនកម្មដោយ ក្រុមប្រឹក្សា នោះចាត់ទុកថាសំណើវិសោធនកម្មត្រូវបានទទួលការអនុម័ត ហើយនឹងចូលជាធរមាន ក្រោយពីរយៈពេលមួយរយប៉ែតសិបថ្ងៃ ឬក្រោយពីថ្ងៃបរិច្ឆេទដូចមានចែងនៅក្នុងសំណើវិសោធនកម្ម ដែលបានស្នើចំពោះរដ្ឋភាគីទាំងនោះដែលមិនបានសំដែងការជំទាស់ ។

៤-រដ្ឋភាគីដែលបានសំដែងការជំទាស់ ទៅនឹងសំណើវិសោធនកម្មអាចទទួលយកជាការវិញ ដោយប្រើមធ្យោបាយជាលិខិតុបករណ៍បញ្ជាក់ពីការព្រមទទួលយក ឬការយល់ព្រមរបស់ខ្លួន នូវ ខ ទាំងឡាយនៃវិសោធនកម្ម ។

៥-ប្រសិនបើរដ្ឋភាគីចំនួន៥ ឬលើសពីនេះបានជំទាស់ទៅនឹងសំណើវិសោធនកម្ម ក្រុមប្រឹក្សា ត្រូវបញ្ជូនសំណើវិសោធនកម្មនេះជូនទៅ គណៈកម្មការ ដើម្បីធ្វើការពិចារណាថែមទៀត ។

៦-ប្រសិនបើសំណើវិសោធនកម្មនេះ មិនត្រូវបានទទួលការអនុម័តយោងតាមកថាខ័ណ្ឌ ៣ នៃមាត្រានេះ ក្រុមប្រឹក្សា អាចកោះប្រជុំជាសន្និសីទនៃបណ្តារដ្ឋភាគីទាំងអស់ ។

## មាត្រា ៨

១-ប្រសិនបើអាច រដ្ឋភាគីត្រូវផ្តល់ទៅក្រុមប្រឹក្សានូវពត៌មានដែលអាចជួយដល់ គណៈកម្មការ ក្នុងការខកខានមិនបានបំពេញមុខងាររបស់ខ្លួន ស្របតាមកថាខ័ណ្ឌ ១ នៃមាត្រា ៦ ។

២-រដ្ឋភាគីត្រូវរក្សាការផ្តល់ដំណឹងដល់ ក្រុមប្រឹក្សា រាល់វិធានការនានាដែល គណកម្មការ បានយកមកអនុវត្តនូវ ខ ទាំងឡាយនៃអនុសញ្ញានេះ ។ ក្រុមប្រឹក្សា ត្រូវប្រាប់ដំណឹងនេះទៅរដ្ឋភាគីទាំងអស់ និងអង្គការអន្តរជាតិនានា ដែលជាប់ពាក់ព័ន្ធ ។

## មាត្រា ៩

ក្រុមប្រឹក្សា ដោយមានកិច្ចសហប្រតិបត្តិការពីរដ្ឋភាគីទាំងអស់ និងអង្គការអន្តរជាតិនានា ដែលជាប់ពាក់ព័ន្ធត្រូវចាត់វិធានការទាំងឡាយសមស្រប ដើម្បីជួយសំរួលដល់ការអនុវត្តន៍នៃអនុសញ្ញានេះ ព្រមទាំង ខ ទាំងឡាយ ស្តីពីជំនួយបច្ចេកទេស និងវិធានផ្សេងៗទៀត សំរាប់ជាការផ្លាស់ប្តូរពត៌មានទៅវិញទៅមកដែលពាក់ពន្ធ័នឹងការអភិវឌ្ឍន៍បច្ចេកទេសក្នុងការដាក់សំគាល់ និងការស្រាវជ្រាវគ្រឿងផ្ទុះ ។

## មាត្រា ១០

ឧបសម្ព័ន្ធបច្ចេកទេសភ្ជាប់ទៅនឹងអនុសញ្ញានេះ បង្កើតជាផ្នែកមួយបន្ថែមទៀតនៃអនុសញ្ញានេះ ។

## មាត្រា ១១

១. ជម្លោះរវាងរដ្ឋភាគី ពីរ ឬច្រើនទៅនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះដែលមិនអាចដោះស្រាយបានតាមការចរចា អាចធ្វើសំណើដោយរដ្ឋភាគីមួយក្នុងចំណោមរដ្ឋភាគីទាំងអស់ទៅគណៈវិនិច្ឆ័យ ។ ប្រសិនបើក្នុងរយៈពេលប្រាំមួយខែគិតចាប់ពីថ្ងៃស្នើសុំធ្វើការវិនិច្ឆ័យ ហើយរដ្ឋភាគីមិនអាចយល់ព្រមលើការរៀបចំរបស់គណៈវិនិច្ឆ័យនេះទេ រដ្ឋភាគីមួយនៃរដ្ឋភាគីទាំងនោះអាចបញ្ជូនជម្លោះឡើងតុលាការយុត្តិធម៌អន្តរជាតិ ដោយធ្វើសំណើអនុលោមតាមលក្ខន្តិកៈរបស់តុលាការ ។

២. នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ផ្តល់ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋភាគីអាចប្រកាសថាខ្លួនមិនបានចាត់ទុកថាត្រូវបានចងភ្ជាប់ដោយកថាខ័ណ្ឌខាងលើទេ ។ រដ្ឋភាគីផ្សេងទៀតនឹងមិនត្រូវបានចងភ្ជាប់ដោយកថាខ័ណ្ឌខាងលើ ចំពោះរដ្ឋភាគីណាមួយដែលបានដាក់លក្ខ័ខ័ណ្ឌបែបនេះដែរ ។

៣.រដ្ឋភាគីណាមួយដែលបានបង្កើតល័ក្ខខ័ណ្ឌ ដោយយោងតាមវាក្យខ័ណ្ឌខាងលើ អាចដកល័ក្ខខ័ណ្ឌនេះវិញបានដោយជូនដំណឹងទៅគណៈកម្មការទទួលបន្ទុក ។

## មាត្រា ១២

លើកលែងចំពោះសេចក្តីដូចមានចែងក្នុងមាត្រា ១១ គ្មានល័ក្ខខ័ណ្ឌណាមួយត្រូវបានដាក់ទៅលើអនុសញ្ញានេះបានឡើយ ។

## មាត្រា ១៣

១. អនុសញ្ញានេះ គឺបើកចំហ ដើម្បីចុះហត្ថលេខានៅក្នុងទីក្រុង ម៉ុងរ៉េអាល់ កាលពីថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៩៩១ ដោយបណ្តារដ្ឋដែលបានចូលរួមក្នុងអង្គសន្និសីទអន្តរជាតិ ស្តីពីច្បាប់អាកាសដែលបានប្រារព្ធឡើងនៅទីក្រុង ម៉ុងរេអាល់ ចាប់ពីថ្ងៃទី ១២ ខែ កុម្ភៈ ដល់ថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៩៩១ ។ បន្ទាប់ពីថ្ងៃទី ១ ខែ មិនា ឆ្នាំ ១៩៩១ អនុសញ្ញានេះ គឺបើកចំហសំរាប់បណ្តារដ្ឋទាំងអស់ដើម្បីចុះហត្ថលេខា នៅទីស្នាក់ការនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ក្នុងទីក្រុង ម៉ុងរេអាល់ រហូតអនុសញ្ញានេះចូលជាធរមាន ដោយអនុលោមតាមកថាខ័ណ្ឌ ៣ នៃមាត្រនេះ ។ រដ្ឋណាដែលមិនចុះហត្ថលេខាលើអនុសញ្ញានេះ អាចទទួលយល់ព្រមតាមអនុសញ្ញានេះនៅពេលណាក៏បាន ។

២. អនុសញ្ញានេះត្រូវស្ថិតនៅក្រោមការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រម ឬការសុំចូលជាសមាជិកពីបណ្តារដ្ឋ ។ លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិក ត្រូវដាក់ជូនអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលត្រូវបានជ្រើសរើសតាមរយៈគណៈកម្មការទទួលបន្ទុក ។ នៅពេលបញ្ជូនលិខិតុបករណ៍នៃការផ្តល់សច្ចាប័នរបស់ខ្លួន រដ្ឋនីមួយៗត្រូវប្រកាសថាជារដ្ឋមានផលិត ឬគ្មានផលិត ។

៣-អនុសញ្ញានេះត្រូវចូលជាធរមានហុកសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបញ្ជូនលិខិតុបករណ៍ ទីសាមសិបប្រាំនៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬសុំចូលជាសមាជិកជាមួយ គណៈកម្មការទទួលបន្ទុក ដោយ បញ្ជាក់ថាមានរដ្ឋមិនតិចជាងប្រាំ បានប្រកាសស្របតាមកថាខ័ណ្ឌ ២ នៃមាត្រានេះថាជារដ្ឋផលិត ។ ប្រសិនបើលិខិតុបករណ៍ចំនួនសាមសិបប្រាំ ដែលត្រូវបានបញ្ជូនមកមុនការបញ្ជូនលិខិតុបករណ៍ ពីរដ្ឋផលិតចំនួនប្រាំ អនុសញ្ញានេះត្រូវចូលជាធរមាន នៅថ្ងៃទីហុកសិប បន្ទាប់ពីថ្ងៃនៃការដាក់បញ្ជូនលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនៃរដ្ឋផលិតទីប្រាំ ។

៤-សំរាប់រដ្ឋដទៃទៀត អនុសញ្ញានេះត្រូវចូលជាធរមានហុកសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិក ។

៥-នៅពេលដែលអនុសញ្ញានេះចូលជាធរមានភ្លាម អនុសញ្ញានេះត្រូវចុះបញ្ជីដោយគណៈកម្មការទទួលបន្ទុក អនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងអនុលោមតាមមាត្រា ៨៣ នៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ (Chicago , ១៩៤៤) ។

## មាត្រា ១៤

គណៈកម្មការទទួលបន្ទុកត្រូវផ្តល់ពត៌មានជាបន្ទាន់ដល់រដ្ឋហត្ថលេខី និងរដ្ឋភាគីទាំងអស់នូវៈ

១-ហត្ថលេខានីមួយៗនៃអនុសញ្ញានេះ និងកាលបរិច្ឆេទនៃអនុសញ្ញានេះ

២-រាល់ការបញ្ជូនលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការសុំចូលជាសមាជិកនិងកាលបរិច្ឆេទនៃការសុំចូលត្រូវផ្តល់សេចក្តីបញ្ជាក់ពិសេសថា តើរដ្ឋនោះបានទទួលស្គាល់ថាខ្លួនជារដ្ឋផលិតដែរ ឬទេ ។

៣-កាលបរិច្ឆេទការចូលជាធរមាននៃអនុសញ្ញានេះ

៤-កាលបរិច្ឆេទការចូលជាធរមាន នូវរាល់ការធ្វើវិសោធនកម្មណាមួយនៃអនុសញ្ញានេះ ឬឧបសម្ព័ន្ធបច្ចេកទេសនៃអនុសញ្ញានេះ

៥- សេចក្តីប្រកាសមិនយល់ព្រមណាមួយបានធ្វើឡើងស្របតាមមាត្រា ១៥ និង

៦- សេចក្តីប្រកាសណាមួយបានធ្វើឡើងស្របតាមវាក្យខ័ណ្ឌ ២ នៃមាត្រា ១១

## មាត្រា ១៥

១-រដ្ឋភាគីមួយអាចប្រកាសមិនយល់ព្រមលើអនុសញ្ញានេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកគណៈកម្មការទទួលបន្ទុក

២-សេចក្តីប្រកាសមិនយល់ព្រមនឹងមានប្រសិទ្ធិភាពរយៈពេលមួយរយប៉ែតសិបថ្ងៃដោយគិតពីថ្ងៃដែលគណៈ

កម្មការទទួលបន្ទុកបានទទួលសេចក្តីជូនដំណឹងនេះ ។

ដើម្បីជាសាក្សី បេសកជនវិសាមញ្ញ និងពេញសមត្ថភាព ជាតំណាងស្របច្បាប់ដែលតែងតាំងដោយ រដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនបានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅទីក្រុង ម៉ុងរេអាល់ ថ្ងៃទី មួយ ខែមិនា ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបមួយ អត្ថបទដើមត្រូវបានសរសេរជាប្រាំភាសាមានតម្លៃស្មើគ្នាគឺ អង់គ្លេស បារាំង រុស្ស៊ី អេស្ប៉ាញ៉ុល និងអារ៉ាប៊ី ។

# ឧបសម្ព័ន្ធ II

## ឧបសម្ព័ន្ធបច្ចេកទេស

### ភាគ ១

### ការពិពណ៌នាពីគ្រឿងផ្ទុះ

I- គ្រឿងផ្ទុះដែលចែងក្នុងកថាខ័ណ្ឌ ១ មាត្រា ១ នៃអនុសញ្ញានេះ គឺគ្រឿងផ្ទុះទាំងឡាយណាដែល :

ក- ត្រូវបានរៀបចំយ៉ាងជាក់លាក់ជាមួយនិងគ្រឿងផ្ទុះមួយ ឬច្រើនដែលទ្រង់ទ្រាយសុទ្ធនៃគ្រឿងផ្ទុះនោះ មានសម្ពាធចំហាយតិចជាង $10^{-4}p_a$ មានសីតុណ្ហភាព ២៥ អង្សាសេ។

ខ- ត្រូវបានរៀបចំយ៉ាងជាក់លាក់ជាមួយនិងសំភារៈភ្ជាប់ឱ្យនៅជុំគ្នា ហើយនិង

គ- ជាគ្រឿងផ្ទុះចំរុះ ទន់ ឬអាចបត់បែនបានទៅតាមសីតុណ្ហភាពនៅក្នុងបន្ទប់ធម្មតា។

II-គ្រឿងផ្ទុះទាំងឡាយនេះ ទោះបីជាកិច្ចប្រជុំបានពិពណ៌នាពីគ្រឿងផ្ទុះនេះ នៅក្នុងកថាខ័ណ្ឌ១ នៃភាគនេះ ក៏នឹងមិនត្រូវបានចាត់ទុកថា ជាគ្រឿងផ្ទុះដរាបណាគ្រឿងផ្ទុះនោះត្រូវបានគេកាន់កាប់ ឬបន្តប្រើប្រាស់សំរាប់បំណងជាក់លាក់ដូចខាងក្រោម ឬនៅតែត្រូវបានធ្វើសាជីវកម្មយ៉ាងច្បាស់លាស់នោះពោលគឺ គ្រឿងផ្ទុះទាំងឡាយណាដែល :

ក-ត្រូវបានផលិតឡើង ឬរក្សាទុកក្នុងបរិមាណបានកំណត់ទុក សំរាប់ការប្រើប្រាស់ស្រាវជ្រាវស្របច្បាប់ ការអភិវឌ្ឍន៍ ការសាកល្បងគ្រឿងផ្ទុះថ្មី ឬគ្រឿងផ្ទុះកែច្នៃ ។

ខ-ត្រូវបានផលិតឡើង ឬរក្សាទុកក្នុងបរិវេណបានកំណត់ទុក សម្រាប់ប្រើប្រាស់ក្នុងការហ្វឹកហ្វឺនស្របច្បាប់ ដើម្បីការរកគ្រឿងផ្ទុះ ហើយនិង ឬការអភិវឌ្ឍន៍គ្រឿងផ្ទុះ ឬសាកល្បងនៃឧបករណ៍រកគ្រឿងផ្ទុះ ។

គ-ត្រូវបានផលិតឡើង ឬរក្សាទុកក្នុងបរិមាណបាកំណត់ទុក សំរាប់តែការប្រើប្រាស់ក្នុងគោលបំណង នៃនីតិវិទ្យាសាស្ត្រស្របច្បាប់ (Forensic Science purposes )

ឃ-ទុកសំរាប់ នឹងដែលត្រូវបានធ្វើសាជីវកម្មដែលជាផ្នែកទាំងស្រុង នៃឧបករណ៍យោធាស្របច្បាប់ក្នុងទឹកដីនៃរដ្ឋផលិត ក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ចំពោះរដ្ឋនោះ ។ ឧបករណ៍នេះ ដែលបានផលិតឡើងក្នុងអំឡុងពេល ៣ឆ្នាំនោះ ត្រូវបានគេចាត់ទុកថា ជាឧបករណ៍យោធាស្របច្បាប់ ដូចមានចែងក្នុងកថាខ័ណ្ឌ ៤ មាត្រា ៤ នៃអនុសញ្ញានេះ ។

III- ក្នុងភាគនេះ

- ស្របច្បាប់ នៅកថាខ័ណ្ឌ ២ ក.ខ និង គមានន័យថា បានអនុញ្ញាតស្របតាមច្បាប់ និងបទបញ្ញា នៃរដ្ឋភាគីដែលជាប់ពាក់ព័ន្ធ ហើយនិង

- គ្រឿងផ្ទុះកំរិតខ្ពស់ ដែលមាននៅក្នុងនោះ ប៉ុន្តែមិនត្រូវកំណត់លើ Cyclotetramethylenetetramine (HMLX) pentaery thritol tettranitrate(PETN) ហើយនិង Cyclotrimethylenetetramine(RDX)

Honduras, the Repolic of
India, the Repolic of
Indonesia, the Repolic of
Iran,Islamic Repolic of
Israel, the State of
Italian Repolic the
Jamaica
Japan
Kenya, the Repolic of
Kuwait, the State of
Lebanese Republic the
Madagascar, the Democratic Republic of
Mali, the Repolic of
Mauritius
Mexican States, the United
Morocco, the Kingdom of
Netherlands, the Kingdom of the
Nigeria, the federal Republic of
Noeway, the Kingdom of
Pakistan, the Islamic Republic of
Paraguay, the Repolic of
Paru, the Repolic of
Poland, the Repolic of
Qatar, the state of
Republic of Korea, the
Romania
Saudi Arrabia, the Kingdom of
Senegal, the Repolic of
Spain, the Kingdom of
Sweden, the Kingdom of
Swiss Confederation, the
Thailand, the Kingdom of
Togolese Republic, the
Trinidad and Tobago, the Repolic of
Tunisia, the Repolic of
Turkey, the Repolic of
Uganda, the Repolic of
Ukrainian Soviet Socailist republic, the
Union of Soviet Socailist republic, the
United Arab Emerates, the
United Kingdom of Great Britain and northern Ireland, the
United Republic of Tanzania, the
United States of America, the
Venezuela, the public of
Zaire, the public of
Zambia, the Republic of

អង្គការអន្តរជាតិខាងក្រោមត្រូវបានធ្វើជាអ្នកតំណាងសង្កេតការណ៍

១- អង្គការសហប្រជាជាតិ ( UN )

២- អង្គការដែនសមុទ្រ ( IMO )

៣- សហគមន៍ដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ ( IAIA)

៤- សហគមន៍អន្តរជាតិ នៃសហគមន៍ក្រុមហ៊ុនអាកាសចរណ៍ PILOT.(IFAPA )

៥- គណៈកម្មការអាកាសចរណ៍ស៊ីវិលអាហ្វ្រិក ( AFCAC )

៦- គណៈកម្មការអាកាសចរណ៍ស៊ីវិលអាមេរិកឡាទីន ( LACAC )

សន្និសីទនេះត្រូវបានប្រកាសបើក និងថ្លែងការណ៍ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិលោក Javer Perez de Cuella ហើយនិងប្រធានក្រុមប្រឹក្សាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ Dr Assad Kotaite ។

សន្និសីទបានបោះឆ្នោតជ្រើសរើស Dr. K.O. Rattray "ប្រទេស Jamaica" ជាប្រធាន Dr.F.A.Cede "ប្រទេស "Austria "Dr.H.A. Perucchi"ប្រទេស"Agentina " លោក M. Mukai " ប្រទេស Jampan " លោក V.Poonoosamy " ប្រទេស Mauritius " ជាអនុប្រធាន ។

អគ្គលេខាធិការនៃសន្និសីទនេះគឺ Dr.S.S Sidhu អគ្គលេខាធិការនៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ។ Dr.Milde នាយកការិយាល័យច្បាប់នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ជាលេខាធិការប្រតិបត្តិនៃសន្និសីទនេះ លោកត្រូវបានជួយជ្រោមជ្រែងដោយ Dr . M . Poucelet មន្ត្រីគោលការណ៍ច្បាប់ លោក R.K. VanDam មន្ត្រីច្បាប់ជាន់ខ្ពស់ លោក G. M. Rakar និងលោក J. V. Augustin មន្ត្រីច្បាប់នៃអង្គការនេះ ហើយនិងមន្ត្រីផ្សេងៗទៀត នៃអង្គការនេះ ។

សន្និសីទនេះ បានបង្កើតគណៈកម្មាធិការមួយដែលប្រធានរបស់វា ជាប្រធានសន្និសីទនេះ ហើយនិងបានបង្កើតគណៈកម្មាធិការដូចខាងក្រោមនេះ :

គណៈកម្មាធិការសារតាំង

-ប្រធាន : Dr. L. Jakubovice (ប្រទេសប្រេស៊ីល )

-សមាជិក: ប្រទេសឆេកូស្លូវ៉ាគី ហ្គាណា លីបង់ ស៊ុយអែត

គណៈកម្មាធិការព្រាងច្បាប់

-ប្រធាន : លោក M. V. Poonoosamy (ប្រទេស Mauritius)

-សមាជិ : ប្រទេស
-Agentina
-Canada
-China
-Côte d'Ivoire
-Czechoslvakia
-Egypt
-France
-Islamic Republic of Iran
-Japan
-Pakistan
-Saudi Arabia

-Union of Soviet Socialist Republic
-United Kingdom
-United states
-Venezuela

បន្ទាប់ពីពិភាក្សាសន្និសីទនេះ បានអនុវត្តដោយមតិកុងសង់ស៊ីស លើអត្ថបទអនុសញ្ញាមួយស្តីពីការកត់សំគាល់គ្រឿងផ្ទុះសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ។ អនុសញ្ញាដែលបានថ្លែងខាងលើនេះត្រូវបានបើកចំហឱ្យចុះហត្ថលេខានៅទីក្រុងម៉ុងរេអាល់នៅថ្ងៃនេះ ម្យ៉ាងទៀតសន្និសីទបានអនុវត្តតាមមតិកុងសង់ស៊ីសលើសេចក្តីដូចខាងក្រោម :

-ដោយហេតុថា មានអំពើខុសច្បាប់ប្រឆាំង ទៅនឹងអាកាសចរណ៍ស៊ីវិល នាវាចរ ហើយនិងវិធីផ្សេងៗទៀត នៃការដឹកជញ្ជូនបានជាប់ទាក់ទិន្នជាញឹកញាប់ទៅនឹងការប្រើប្រាស់គ្រឿងផ្ទុះ និងសំភារៈគ្រឿងផ្ទុះ ឬ

-ដោយហេតុថា ការកំណត់សំគាល់គ្រឿងផ្ទុះប្លាស្ទិកសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក និងជួយឱ្យរដ្ឋទប់ស្កាត់អំពើបែបនេះ

-ដោយសំគាល់ថា សារសំខាន់ចំពោះរដ្ឋទាំងអស់អាចរកមធ្យោបាយសមរម្យដល់ការរកឱ្យឃើញនេះ

-ដោយទទួលស្គាល់ថា ការអនុវត្តនីមធ្យោបាយបែបនេះអាចបណ្តាលឱ្យមានការលំបាកចំពោះរដ្ឋខ្លះនោះ

-ដោយយល់ឃើញចំពោះបំណងប្រាថ្នានៃកិច្ចការបន្ថែម ដែលទាក់ទងក្នុងការរកឃើញគ្រឿងផ្ទុះ ក្រៅអំពីគ្រឿងផ្ទុះប្លាស្ទិកដែលអាចត្រូវបានប្រើប្រាស់សំរាប់អំពើខុសច្បាប់នោះ ។

-ដោយកត់សំគាល់ថា មានការចាប់អារម្មណ៍ជាបន្តបន្ទាប់របស់អង្គការសហប្រជាជាតិ និងជាពិសេសរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ហើយនិងអង្គការដែនសមុទ្រអន្តរជាតិនោះ សន្និសីទ :

១-ជំរុញរដ្ឋឱ្យក្លាយជាភាគី ចំពោះអនុសញ្ញាស្តីអំពីការកត់សំគាល់គ្រឿងផ្ទុះប្លាស្ទិក សំរាប់បំណងការរកឃើញឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

២-អំពាវនាវរដ្ឋដែលផលិតគ្រឿងផ្ទុះប្លាស្ទិក ឱ្យអនុវត្តការកត់សំគាល់គ្រឿងផ្ទុះបែបនេះឱ្យបានឆាប់បំផុត ។

៣-ស្នើរដ្ឋទាំងឡាយឱ្យបន្តជំរុញលើកទឹកចិត្តធ្វើការស្រាវជ្រាវ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យប្រសើរ និងតាមមធ្យោបាយសេដ្ឋកិច្ចនៃការរុករកឱ្យឃើញទាំងអស់នូវភ្នាក់ងារកត់សំគាល់ ដែលបានបញ្ជាក់ច្បាស់លាស់នៅក្នុងអនុសញ្ញានេះ ។

៤-ជំរុញសហគមន៍អន្តរជាតិ ឱ្យពិចារណាបង្កើននូវជំនួយបច្ចេកទេសហិរញ្ញវត្ថុ និងសំភារៈដល់រដ្ឋដែលត្រូវការជំនួយបែបនេះ ដើម្បីអាចទទួលយកប្រយោជន៍ពីស្នាដៃនៃបំណង និងគោលដៅ ក្នុងអនុសញ្ញានេះ ជាពិសេសតាមរយៈកម្មវិធីជំនួយបច្ចេកទេស នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ។

៥-អញ្ជើញក្រុមប្រឹក្សានៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិដើម្បី :

ក- ទទួលកាន់កាប់តំណែងដែលបានចែងក្នុងអនុសញ្ញានេះ

ខ-រក្សាទុកនូវអត្ថិភាពក្រុម Ad Hoc ដែលមានស្រាប់នូវជំនាញខាងការរកឃើញគ្រឿងផ្ទុះ ដើម្បីជួយឱ្យអ្នកជំនាញនេះបន្តការសិក្សា ដែលអាចរក្សាឧប្បសម្ព័ន្ធបច្ចេកទេសចំពោះអនុសញ្ញាឱ្យបានទំនើប ដោយរង់ចាំចូលជាធរមាន

នៃអនុសញ្ញានេះ និងបង្កើតគណៈកម្មការបច្ចេកទេសគ្រឿងផ្ទុះអន្តរជាតិ

គ-គោរពគោលការណ៍នៃការតំណាងភូមិសាស្ត្រ សមធម៌ ក្នុងការតែងតាំងសមាជិក នៃគណកម្មការបច្ចេកទេសគ្រឿងផ្ទុះអន្តរជាតិ

៦-ស្នើសុំអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីផ្តួចផ្តើមគំនិតសិក្សាក្នុងវិធីសាស្ត្រ នៃការរកឃើញគ្រឿងផ្ទុះ និងសំភារៈគ្រឿងផ្ទុះ ជាបញ្ហាដែលមានអទិភាពខ្ពស់ ជាពិសេសក្នុងការកត់សំគាល់គ្រឿងផ្ទុះទាំងនោះ ក្រៅអំពីគ្រឿងផ្ទុះប្លាស្ទិកដែលគេបានរកឃើញវា ដោយបានជំនួយដោយការប្រើប្រាស់ភ្នាក់ងារសំគាល់ បើសិនជាត្រូវការចាំបាច់ ដោយតាមការវិវឌ្ឍន៍ច្បាប់ដ៏ទូលំទូលាយដ៏សមស្របមួយ ។

ដើម្បីជាសាក្សី ប្រតិភូនៃរដ្ឋស្របច្បាប់ បានចុះហត្ថលេខាលើសេចក្តីសំរេចចិត្តចុងក្រោយនេះ ។

ធ្វើនៅទីក្រុងម៉ុងរេអាល់ ថ្ងៃទីមួយ ខែមីនា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបមួយ អត្ថបទប្រាំច្បាប់មានតំលៃស្មើគ្នា សរសេរប្រាំភាសាមាន អង់គ្លេស បារាំង រុស្ស៊ី អេស្ប៉ាញ៉ុល ហើយនិង អារ៉ាប៊ិក ។

ច្បាប់ថតចំលងមួយច្បាប់ ត្រូវបានដាក់ជូនជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិ ហើយច្បាប់ថតចំលងដ៏ជាក់លាក់មួយនៃច្បាប់ថតចំនងនេះត្រូវបានផ្ញើរជូនដោយអង្គការខាងលើនេះ ទៅឱ្យរដ្ឋាភិបាលនីមួយៗ ដែលជាតំណាងនៅឯសន្និសីទនេះ ។

## ភាគ២

## សារធាតុភ្ជាក់ងាររុករក

-សារធាតុភ្ជាក់ងាររុករកគឺ ជាសារធាតុមួយនៃសារធាតុទាំងឡាយ ដែលបានចែងក្នុងតារាងខាងក្រោមនេះ សារធាតុភ្ជាក់ងាររុករកដែលបានពិពណ៌នានៅក្នុងតារាងនេះ គឺក្នុងគោលបំណងឱ្យប្រើប្រាស់ដើម្បីលើកស្ទួយសមត្ថភាពរុករកឱ្យឃើញគ្រឿងផ្ទុះ តាមមធ្យោបាយប្រើប្រាស់ការរកឃើញចំហាយ។ ក្នុងករណីនីមួយៗការដាក់បញ្ចូលសារធាតុភ្ជាក់ងាររុករកទៅក្នុងគ្រឿងផ្ទុះនេះ នឹងត្រូវបានធ្វើឡើងក្នុងលក្ខណៈបែបណាមួយ ដើម្បីឱ្យលាយចូលសាច់មួយស្មើដៃគ្នា ក្នុងផលិតផលបញ្ចប់ ។

នៅពេលផលិត ការប្រមូលផ្តុំអប្បបរមានៃសារធាតុភ្ជាក់ងាររុករក ក្នុងផលិតផលបញ្ចប់ ការផលិតនឹងត្រូវបានបង្ហាញនៅក្នុងតារាងដូចខាងក្រោម ៖

**តារាង១**

| ឈ្មោះសារធាតុភ្ជាក់ងាររុករក | រូបមន្ត Molecular | ទំងន់ Molecular | ការប្រមូលផ្តុំអប្បបរមា |
|---|---|---|---|
| Ethrylene glycol-dinitrate(EGDN) | C2H4(NO1)2 | 152 | 0.2% by mass |
| 2,3Dimcthy 1-2-3 dinitrobutan (DMNB) | C6G12(NO2)2 | 176 | 0.1% by mass |
| Para-mononitroluen (P-MNT) | C7H7NO2 | 137 | 0.5% by mass |
| Otho-mononitrotoluene (O-MNT) | C7H7NO2 | 137 | 0.5% by mass |

-គ្រឿងផ្ទុះណាមួយក៏ដោយ ដែលជាលទ្ធផលនៃការដាក់បញ្ចូលដោយរូបមន្តជាធម្មតារបស់ខ្លួន មានផ្ទុកទៅដោយសារធាតុភ្ជាក់ងាររុករកគ្រឿងផ្ទុះដូចបានកំណត់ ឬប្រមូលផ្តុំកិតអប្បបរមា ដូចដែលបានគូរខាងលើ ចាត់ទុកថាជាគ្រឿងផ្ទុះសំគាល់បាន ។

## ឧបសម្ព័ន្ធ III

## សេចក្តីសម្រេចចុងក្រោយ

### នៃសន្និសីទអន្តរជាតិស្តីពីច្បាប់ដែនអាកាស ដែលបានប្រព្រឹត្តទៅ
### ក្រោមការឧបត្ថម្ភ នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ នៅក្នុងខែកុម្ភៈ និងមិនា ១៩៩១

អ្នកតំណាងរដ្ឋ ដែលពេញសមត្ថកិច្ចនៅសន្និសីទអន្តរជាតិស្តីពីច្បាប់ដែនអាកាស ដែលប្រព្រឹត្តក្រោមការឧបត្ថម្ភ របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ បានប្រជុំគ្នានៅទីក្រុងម៉ុងរេអាល់ ចាប់ពីថ្ងៃទី ១២ កុម្ភៈ ដល់ថ្ងៃទី ០១ មីនា ឆ្នាំ១៩៩១ ដើម្បីពិចារណាសេចក្តីព្រាងអនុសញ្ញាមួយស្តីពីការកំណត់សំគាល់ គ្រឿងផ្ទុះផ្លាស្ទិកសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក ដែលបានរៀបចំដោយគណៈកម្មាធិការច្បាប់ នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ។

រដ្ឋាភិបាលនៃរដ្ឋចំនួន ៩៧ ខាងក្រោមបានធ្វើជាតំណាងឱ្យ នៅក្នុងសន្និសីទនេះ មាន :

Afghanistan, the Republic of
Algeria, the People's Democratic Republic of
Argentine Republic. the
Australia
Austria. the Republic of
Belgium. the kingdom of
Belize
Bolivia. the Republic of
Brazil. the Federative Republic of
Bulgaria. the people's Republic of
Byelorussian Sovict Socialist Republic. the
Canada
Carpe Verd. the Republic of
Chile, the Repolic of
China, the People's Republic of
Colombia, the Repolic of
Costa Rica, the Repolic of
Cote d' Iviore the Repolic of
Coba, the Repolic of
Czech Slovak Federal Repolic, the
Denmark, the kingdom of
Ecuador, the Repolic of
Egypt, the Arab Repolic of
Ethiopia, the people's Democratic Repolic of
Finland, the Repolic of
French Repolic of
Gabonese Republic, of
Germany, the Federal Republic of
Ghana, the Repolic of
Guinea-Bissau, the Repolic of
Hellenic the Repolic of
Holy See, the Repolic of

## ឧបសម្ព័ន្ធ IV

### អនុសញ្ញាស្តីពីការកត់សំគាល់គ្រឿងផ្ទុះប្លាស្ទិកសំរាប់ជាកម្មវត្ថុនៃការស្រាវជ្រាវរក បានចុះហត្ថលេខានៅទីក្រុង ម៉ុងរ៉េអាល់ នៅថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩១

| ឈ្មោះរដ្ឋ | កាលបរិច្ឆេទចុះហត្ថលេខា | ថ្ងៃដាក់លិខិតុបករណ៍នៃសច្ចាប័ន ការព្រមទទួល ការយល់ព្រម ឬ ការសុំចូលជាសមាជិក | ថ្ងៃចាប់ប្រតិបត្តិ |
|---|---|---|---|
| Afghanistan | 1 March 1991 | | |
| Argentina | 1 March 1991 | | |
| Belgium | 1 March 1991 | | |
| Belize | 1 March 1991 | | |
| Bolivia | 1 March 1991 | | |
| Brazil a / | 1 March 1991 | | |
| Byelorussian Soviet Socialist Republic | 1 March 1991 | | |
| Canada | 1 March 1991 | | |
| Chile | 1 March 1991 | | |
| Costa Rica | 1 March 1991 | | |
| Cote d ′ Ivoire | 1 March 1991 | | |
| Czechoslovakia | 1 March 1991 | | |
| Denkark | 1 March 1991 | | |
| Ecuador | 1 March 1991 | | |
| Egypt | 1 March 1991 | | |
| France | 1 March 1991 | | |
| Gabon | 1 March 1991 | | |
| Germany | 1 March 1991 | | |
| Ghana | 1 March 1991 | | |
| Greece | 1 March 1991 | | |
| Guinea | 1 March 1991 | | |
| Guinea- Bissau | 1 March 1991 | | |
| Israel | 1 March 1991 | | |
| Italy | 1 March 1991 | | |
| Kuwait | 1 March 1991 | | |

* អនុលោមតាមមាត្រា១៣កថាខ័ណ្ឌ៣អនុសញ្ញានេះត្រូវចូលជាធរមាន៦០ថ្ងៃក្រោយពីថ្ងៃដាក់លិខិតុបករណ៍ថ្ងៃនៃសច្ចាបន័ ការព្រមទទួល ឬការយល់ព្រម ឬការសុំចូលជាសមាជិក អោយតែរដ្ឋបែបនេះមិនតិចជាង០៥ថ្ងៃបានប្រកាសថារដ្ឋនេះជារដ្ឋអ្នកផលិតអនុលោមតាមកថាខ័ណ្ឌ២ នៃមាត្រាដដែលនេះ

| ឈ្មោះរដ្ឋ | កាលបរិច្ឆេទចុះហត្ថលេខា | ថ្ងៃដាក់លិខិតុបករណ៍នៃសច្ចាប័ន ការព្រមទទួល ការយល់ព្រម ឬ ការសុំចូលជាសមាជិក | ថ្ងៃចាប់ប្រតិបត្តិ |
|---|---|---|---|
| Lebanon | 1 March 1991 | | |
| Madagascar | 1 March 1991 | | |
| Mali | 1 March 1991 | | |
| Mauritius | 1 March 1991 | | |
| Mixico | 1 March 1991 | | |
| Norway | 1 March 1991 | | |
| Pakistan | 1 March 1991 | | |
| Peru a/ | 1 March 1991 | | |
| Republic of Korea | 1 March 1991 | | |
| Senegal | 1 March 1991 | | |
| Switzeland | 1 March 1991 | | |
| Togo | 1 March 1991 | | |
| Ukrainian Soviet Socialist Republic | 1 March 1991 | | |
| Union of Soviet Socialist Republics | 1 March 1991 | | |
| United Kingdom of Great Britain and Northern Ireland | 1 March 1991 | | |
| United States of American | 1 March 1991 | | |

ក - ខ ដាក់លក្ខខណ្ឌ : មិនចាត់ទុកខ្លួនឯងថា គោរពតាមមាត្រា ១១ កថាខ័ណ្ឌ១ក្នុងសញ្ញានេះ ។